# ៥- រឿង សង្គ្រាមរវាងគីង្គក់នឹងតាព្រហ្ម

សម័យព្រេងនាយ វេលាមួយ ពិភពលោកកើតទុរ្ភិក្សក្តៅហួតហែងគ្រប់ទិសទី ព្រះពិរុណមិនបង្អុរភ្លៀងសោះ ស្ទឹងត្រពាំង ថ្លុកបឹងព្រែកទន្លេរីងទឹកអស់ ។ សត្វទាំងឡាយស្លាប់គរផ្អើងលើគ្នារុក្ខជាតិនានាស្វិតក្រៀមក្រញ៉ង់ ។ ពួកមណ្ឌកសត្វមានគីង្គក់ ហ៊ីង កង្កែបជាដើម ដែលជាសត្វប៉ិនអត់ធន់ក៏ស្គមនៅតែស្បែកនិងឆ្អឹង ។ ថ្ងៃមួយ គីង្គក់ជាមេប្រកាសដល់ក្រុមញាតិ និង ហ៊ីងកង្កែបជាមិត្តថា " ហៃមិត្តទាំងអស់គ្នា ! មើលទៅតាព្រហ្មមិនបង្អុរភ្លៀងមកឱ្យយើងទេ បើយើងនៅស្ងៀមមុខជាដាច់ពោះស្លាប់មក រឺយមិត្តយើងកេណ្ឌគ្នាទៅតយុទ្ធ នឹងតាព្រហ្មយកភ្លៀងឱ្យបាន អាសន្នដល់ហើយស្ងៀមក៏ស្លាប់ច្បាំងក៏ស្លាប់ បើម្ល៉ឹងស្លាប់ៗក្នុងចម្បាំងយកជ័យឱ្យក្រុមញាតិនិងមិត្តប្រសើរជាងមក ! មក ! ទៅប្រយុទ្ធ " ។ ក្រោយដែលបានប្រកាសយ៉ាងនេះ ពលគីង្គក់និងមិត្តទាំងអស់ក៏លើកព្យុហយាត្រាទៅតយុទ្ធនឹងតាព្រហ្ម ក្នុងវិមានលោកព្ធដ៏អាកាស ។ កងទ័ពមណ្ឌកសត្វដើរកាត់ទីវាល បន្តិចមកស្រាប់តែប្រទះនូវទ័ពមួយហ្វូងធំទៀត ។ មេបញ្ជាការធំនៃទ័ពគីង្គក់ឃើញហ្វូងពលត្រីអណ្តែងធំៗខ្មាន់ខ្មាប់ ខ្លួនប្រឡាក់ស្រមកដោយកម្ទេចធូលីនិងផេះនៃវាលស្រែ ។ មេគីង្គក់សួរថា " នែរឺយតើកនឯងទៅណាបានជាប្រមៀលខ្លួនហុយដីទ្រលោមកាត់មុខឱ្យរំខានដល់កងទ័ពអញនេះ ? " ។ ត្រីអណ្តែងជាមេទ័ពតបថា " ភឿនអើយ ! ពួកមច្ឆាបានបញ្ជូនយើងឱ្យមកជាមួយបងក្រាញ់ដ៏ប៉ិនប្រសប់ខាងរត់ឆ្លងភ្នំ និងបារាយណ៍ ដើម្បីច្បាំងនឹងតាព្រហ្មយកភ្លៀងមកបំពេញបឹងស្ទឹងយើងទៅ ! ទៅ ! ភឿន ! " ។ គីង្គក់ឮដូច្នោះអរណាស់ក៏ប្រាប់កងទ័ពខ្លួន ។ មួយរំពេចនោះស័ព្ទជយោបានលាន់ឮចេញពីទ័ពទាំងពីរក្រុម ហើយទ័ពទាំងនោះក៏ប្រមូលគ្នាជាទ័ពមួយយាត្រាទៅតាមវាលក្តៅហួតហែង ។ ទៅបន្តិចទៅ ស្រាប់តែឃើញបាណកជាតិមួយហ្វូងធំ ហើរខ្មៅ ខ្ទាប់ឮសូរងូងៗលើអាកាស ហើយឮឃ្មុំនិងឪម៉ាល់ជាមេទ័ព បន្លឺមកថា " នែបងគីង្គក់ ហ៊ីង កង្កែប ត្រីអណ្តែង ត្រីក្រាញ់ ឯងទៅណាខ្លួន

ស្រមកយ៉ាងនេះ ? " ។ គីង្គក់តបថា " មករឺយ ! បងឃ្មុំ ! យើងដឹងហើយថា ក្រុមបងលើកទ័ពទៅច្បាំង ព្រោះអត់ភ្លៀងខ្វះឈើព្រៃផ្តល់ផ្កាធ្វើសំបុកដល់ក្រុមបង មកកុំបង្អង់យើងព្រួតគ្នាទៅតយុទ្ធនឹងតាព្រហ្មកុំខ្លាចស្លាប់ ទៅ ! ទៅ ! " ។ ទ័ពគោកនិងអាកាសហ៊ោយកជ័យ ហើយក៏លើកតទៅទៀត ។ លុះដល់ជិតចំការស្ពួតមួយស្រាប់តែទ័ពនេះប្រទះនឹងផ្លែត្រសក់ស្រូវរដូករណែលលើផែនដី ដាច់របេះចាកទងគួរឱ្យអាសូរ ។ ត្រសក់មួយស្រែកដោយមានសង្ឃឹមថា " ភឿនអើយឱ្យគ្នាយើងដោយសារទៅផង តែខំយើងស្ពួតស្លាប់អស់ហើយ ភឿនទៅច្បាំងយើងក៏ស៊ូស្លាប់ជំនួសគ្រួសារយើងដែរ មិនឱ្យនៅវេទនាទេ " ។ មេទ័ពទាំងបី ក៏យល់ព្រមឱ្យត្រសក់ស្រូវប្រមៀលខ្លួនទៅតាមក្បួន ។ លុះផុតពីវាល ក៏បានដល់ព្រៃមួយដែលរុក្ខជាតិទាំងឡាយក្រៀមរញមស្លាប់ជិតអស់ ។ កងទ័ពបានទៅដល់ឃើញវល្លិផ្តៅធំៗ ពីរដើមនៅនឹងគល់ឈើងាប់មួយដើម ។ ផ្តៅសួរថា " នែភឿនទៅណាហ្នឹងក៏សន្ធឹកម្ល៉េះ ភឿនមិនអាសូរមិត្តរុក្ខជាតិគ្នាយើងទេឬ ? ឃើញទេ ស្លាប់ដេកពពូនដោយដៃតាព្រហ្មអស់ហើយ ឱ្យយើងទៅច្បាំងផង យើងនៅយ៉ាងនេះ ក៏វេទនាណាស់ យើងស៊ូទៅស្លាប់ក្នុងសង្គ្រាម ដើម្បីដណ្តើមយកជ័យមកផ្តល់ជីវិតសត្វលោក " ។ ទ័ពទាំងអស់ក៏យល់ព្រមឱ្យផ្តៅគោចរទៅតាមផង ។

ក្រោយមក ទ័ពទាំងអស់ក៏បានដល់ឋានតាព្រហ្ម ។ គីង្គក់បានបញ្ជាឱ្យឃ្មុំប្រុងវាយសម្រុក នៅខ្លោងទ្វារខាងមុខ និង ខាងក្រោយត្រីអណ្តែងត្រីក្រាញ់ដែលខ្លួនប្រឡាក់ទៅដោយក្បុងនិងផេះឱ្យចូលទៅក្នុងពាងនិងផើងទឹកនៅមាត់ទ្វារក្រោយ និងពាងផ្សេងៗ ឱ្យតែមានទឹក ។ ផ្តៅទាំងពីរធំៗ ឱ្យឈរប្រុងនៅមាត់ទ្វារប្រាសាទ ត្រសក់ស្រូវឱ្យប្រមៀលទៅទៀបជើងក្រោមអាសនៈតាព្រហ្មគង់ ។ ឯក្រុមគីង្គក់ ហ៊ីង កង្កែបជាទ័ពស្រួចអ្នកចូលលុក ។ លុះចាត់ស្រេចហើយទ័ពមណ្ឌកសត្វក៏ចូលស្រ តម្រង់អាសនៈតាព្រហ្មអាស្រ័យនៅដោយស្រែកហ៊ោសន្ធាប់យ៉ាងខ្លាំង ធ្វើឱ្យពលរេហ៍អស់ទាំងទេវតា មេនំ មេនាង ចៅជិត ចៅចម ម៉ម ខុនណាងជំទាវ រត់ចេញពីប្រាសាទស្លន់ស្លោទៅត្រូវទឹកផេះទឹកក្បុងដែលត្រីអណ្តែងត្រីក្រាញ់បាចមកលើភ្នែកផ្សាស្រវាំងរកទិសតំបន់ពុំឃើញថែមទាំងត្រូវពួកឃ្មុំ ឪម៉ាល់ទិច ចុកឈឺរមួល ស្រែកយំរំពង ។ តាព្រហ្មរកច្រកចេញពុំទាន់ ស្រែកសួរថា " នែរឺយ ! អាពួកគីង្គក់ ហ៊ីងកង្កែប ចង្រៃឯងទៅណា ? " ។ ពួកមណ្ឌកសត្វតបថាយើងមកច្បាំងៗ " ។ តាព្រហ្មចុះចាកអាសនៈឥតមើលក្រោម ក៏ជាន់លើត្រសក់ស្រូវរអិលដួលផ្ងារស្រទាំង ត្រូវផ្តៅទាំងពីរបន្ទន់ខ្លួនប្រញាប់សង្កត់កជាប់ ឃ្មុំក៏ទិចឈឺផ្សាស្រែកចុះញ៉មពួកសត្វនិងរុក្ខជាតិថា " ចាញ់ហើយ ! " ។ ឮដូច្នោះ មេបញ្ជាការគីង្គក់ក៏ឃាត់ទ័ពឱ្យឈប់ដើម្បីដោះស្រាយបញ្ហាចុះចាញ់ ។ គីង្គក់សួរទៅតាព្រហ្មបរាជ័យថា " ម៉េចក៏លោកបង្អត់ភ្លៀងដល់សត្វលោក ធ្វើឱ្យស្លាប់គ្រប់កន្លែងដូច្នេះ ? គ្នាយើងមិនសុខចិត្តទេ បើលោកមិនបង្អុរភ្លៀងចុះទៅនោះយើងនឹងកម្ទេចវិមានលោក សម្លាប់ទាំងពល ទាំងលោកពុំខាន " ។ តាព្រហ្មនឹកភ័យក៏និយាយអង្វរអស់ពលសត្វនិងរុក្ខជាតិថា " សូមពួកព្រះស្តែងកុំខឹង យើងខ្លាចហើយ យើងនឹងផ្តល់ទឹកភ្លៀងឱ្យឥឡូវនេះហើយ សូមអស់អ្នកអញ្ជើញទៅវិញចុះកុំខឹងអី " ។ គីង្គក់តបថា " ទេ ! កនយើងមិនព្រមទេ បើយើងទៅ នោះលោកនឹងផ្តល់ភ្លៀងឱ្យយើងតែមួយមេហើយព្រងើយកន្តើយទៅ នាំឱ្យពិបាកយើងលើកទ័ពឡើងមកទៀត ដូច្នេះសូមលោកសន្យាឱ្យពរពិសេសដល់យើងសិន ទើបកនយើងសុខចិត្ត " ។ លុះជញ្ជឹងមួយសន្ទុះ តាព្រហ្មក៏ពោលថា " អើ ! យើងព្រមឱ្យពរដល់អ្នករាល់គ្នាហើយ បើដូច្នេះពេលណាអ្នកត្រូវការភ្លៀង ចំណែកគីង្គក់ហ៊ីង កង្កែបត្រូវសង្កៀតធ្មេញ បន្លឺសំឡេងពីក្រោមមក ពេលនោះ យើងនឹងបង្អុរឱ្យអ្នកភ្លាម " ។ កាលសន្យារួចស្រេចទ័ពមណ្ឌកសត្វបាណកសត្វ និងរុក្ខជាតិក៏ថយមកលំនៅរៀងៗខ្លួន ។ តាំងពីនោះមកពេលណាគីង្គក់ ហ៊ីង កង្កែប ត្រូវការភ្លៀង ក៏សង្កៀតធ្មេញបន្លឺសំឡេងក្រតៗ ! អែបៗ ! អោកៗ! ហ៊ីងហ៊ងៗ ! ភ្លៀងក៏ធ្លាក់មក ។